នៅឆ្នាំនេះ បេតិកភណ្ឌវប្បធម៌ និងបុរាណវិទ្យានៃប្រទេសកម្ពុជាត្រូវបានផ្តល់កិត្តិយសជាពិសេស តាមរយៈការរៀបចំសន្និសីទអន្តររដ្ឋាភិបាលស្តីពីអង្គរ និងការប្រជុំគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់អង្គរ ហៅកាត់ថា ICC អង្គរ កាលពីខែធ្នូ២០១៣ ដោយមានការចូលរួមពីសំណាក់លោកជំទាវ អូរ៉េលី ហ្វីលីប៉េទី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងគមនាគមន៍នៃប្រទេសបារាំង។ នៅក្នុងឱកាសនោះ លោកជំទាវបានគូសបញ្ជាក់សារជាថ្មីពីការប្តេជ្ញាចិត្តរបស់បារាំងក្នុងការចូលរួមយ៉ាងសកម្មក្នុងការអភិរក្សតំបន់អង្គរ។ ជាងនេះទៅទៀត ការជ្រើសរើសអោយប្រទេសបារាំង និងជប៉ុនបន្តធ្វើជាសហប្រធាននៃគណៈកម្មការ ICC អង្គរ គឺជាសញ្ញាដ៏ល្អមួយ។ នៅក្នុងបរិបទវប្បធម៌នេះ សារមន្ទីរហ្គីម៉េនៅទីក្រុងប៉ារីស៍បានរៀបចំពិព័រណ៍មួយលើប្រធានបទ "អង្គរ ដើមកំណើតនៃទេវកថា" ដោយទទួលបានអ្នកទស្សនាចំនួន១០៥ ០០០នាក់ពីខែតុលា ឆ្នាំ២០១៣ ដល់ខែមករា ឆ្នាំ២០១៤។ ជោគជ័យនេះបានឆ្លុះបញ្ចាំងសារជាថ្មីពីចំណាប់អារម្មណ៍របស់ប្រជាជនបារាំងចំពោះវប្បធម៌ខ្មែរ។ ជាងនេះទៅទៀត កាលពីខែឧសភាឆ្នាំមុន ការសម្តែងរបាំព្រះរាជទ្រព្យនៅប្រទេសបារាំង និងនៅទ្វីបអឺរ៉ុបក៏បានទទួលជោគជ័យធំធេងផងដែរ។ ព្រឹត្តិការណ៍សំខាន់ចុងក្រោយ គឺកាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៤ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ទ្រង់បានយាងចូលរួមនៅក្នុងសិក្ខាសាលាមួយនៅបណ្ឌិតសភាអក្សរចារឹក និងអក្សរសាស្ត្រនៃប្រទេសបារាំងលើប្រធានបទ "ពីរទសវត្សរ៍នៃកិច្ចសហប្រតិបត្តិការបុរាណវិទ្យាបារាំង-កម្ពុជានៅអង្គរ" ។

ព្រឹត្តិការណ៍គួរអោយកត់សំគាល់មួយទៀតនៅឆ្នាំនេះ គឺទីភ្នាក់ងារអភិវឌ្ឍន៍បារាំង(AFD)បានពង្រឹងតួនាទីរបស់ខ្លួនក្នុងចំណោមដៃគូផ្តល់ជំនួយអភិវឌ្ឍន៍សំខាន់ៗដល់ប្រទេសកម្ពុជា តាមរយៈការចុះហត្ថលេខាលើឥណទានសម្បទានលើកទី១ចំនួន៣៣លានដុល្លារ កាលពីខែធ្នូ ឆ្នាំ២០១៣សំរាប់គាំទ្រគំរោងក្នុងវិស័យធារាសាស្ត្រ និងហិរញ្ញប្បទានមួយទៀតចំនួន២៤លានដុល្លារកាលពីខែមីនាឆ្នាំ២០១៤សំរាប់គំរោងទទួលបានទឹកស្អាត និងអគ្គិសនីជនបទ។ កសិកម្មនៅតែជាវិស័យអាទិភាពសំរាប់ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ដោយហេតុថាប្រជាជនខ្មែរ៦០%គឺជាកសិករ។ ទីភ្នាក់ងារ AFD ផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការអភិវឌ្ឍកសិកម្មជាលក្ខណៈគ្រួសារ ដើម្បីអោយកសិផលទទួលបានទិន្នផលខ្ពស់ និងមានទីផ្សារប្រសើរជាងមុន។ ការបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងវិស័យសំខាន់ៗនៃសេដ្ឋកិច្ចកម្ពុជា(ពិសេសក្នុងផ្នែកទេសចរណ៍ និងវាយនភ័ណ្ឌ) គឺជាទិសដៅមួយទៀតនៃអន្តរាគមន៍របស់ទីភ្នាក់ងារ AFD ដើម្បីជួយអោយប្រទេសកម្ពុជាធ្វើសមាហរណកម្មតំបន់បានកាន់តែប្រសើរមុនពេលបង្កើតទីផ្សាររួមអាស៊ាន។

ជាទីបញ្ចប់ ប្រទេសកម្ពុជាបន្តចូលរួមដោយគ្មានស្ទាក់ស្ទើរក្នុងប្រតិបត្តិការថែរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ។ កងទ័ពកម្ពុជាបំពេញបេសកកម្មរបស់ខ្លួន (ផ្នែកសុខាភិបាល ការបោសសំអាតមីន និងការរក្សាសណ្តាប់ធ្នាប់) ប្រកបដោយលក្ខណៈវិជ្ជាជីវៈខ្ពស់ក្នុងស្ថានភាពដ៏លំបាកបំផុត។ សមត្ថភាពក្នុងការចុះប្រតិបត្តិការនៃកងទ័ពមួកខៀវកម្ពុជាត្រូវបានពង្រឹងតាមរយៈការហ្វឹកហ្វឺននៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម ក្រោមការគាំទ្រពីប្រទេសបារាំង។ កាលពីខែមីនាឆ្នាំ២០១៤ ប្រទេសកម្ពុជាបានបញ្ជូនកងកម្លាំងរបស់ខ្លួនជាលើកដំបូងទៅកាន់ប្រទេសម៉ាលី ហើយត្រូវបានដាក់ពង្រាយនៅភាគខាងជើងនៃប្រទេសនេះដោយមានជំនួយសំភារៈ និងបច្ចេកទេសពីប្រទេសបារាំង។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមគោរពវិញ្ញាណក្ខន្ធទាហានកម្ពុជាដ៏ក្លាហានពីររូប ដែលបានបាត់បង់ជីវិតកាលពីដើមខែមិថុនាក្នុងពេលបំពេញបេសកកម្មនៅម៉ាលី ហើយខ្ញុំសូមចូលរួមរំលែកទុក្ខគ្រួសារសព។

ជាចុងក្រោយ ខ្ញុំសូមសំដែងនូវក្តីសោមនស្សរីករាយចំពោះសហគមន៍បារាំងនៅកម្ពុជា ជាពិសេសការមកបណ្តាក់ទុនដ៏ច្រើនរបស់អ្នកជំនួញបារាំង ដើម្បីពង្រឹងវត្តមានសេដ្ឋកិច្ចរបស់បារាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំណងមិត្តភាពទ្វេភាគីនឹងកាន់តែរឹងមាំឡើងតាមរយៈកំណើននៃការផ្លាស់ប្តូរ និងពិពិធកម្មពាណិជ្ជកម្ម ។ ខ្ញុំសូមថ្លែងអំណរគុណដល់តួអង្គនានា ទាំងបារាំង និងកម្ពុជា ដែលបានចូលរួមក្នុងសកម្មភាពនេះ។

ខ្ញុំសូមជូនពរលោកអ្នកជួបប្រទះជោគជ័យគ្រប់ភារកិច្ច ក្នុងឱកាសនៃទិវាបុណ្យជាតិបារាំងថ្ងៃ១៤ កក្កដា ឆ្នាំ២០១៤នេះ។



**ហ្សង់ក្លូដ ពាំបឺហ្វ**
ឯកអគ្គរដ្ឋទូតបារាំងប្រចាំកម្ពុជា




© ស្ថានទូតបារាំងប្រចាំកម្ពុជា




© ស្ថានទូតបារាំងប្រចាំកម្ពុជា



© ស្ថានទូតបារាំងប្រចាំកម្ពុជា



© វិទ្យាស្ថានបារាំងនៅកម្ពុជា

# EPHEMERIDE

## ២០១៣ ២០១៤

**វគ្គបណ្ដុះបណ្ដាលបច្ចេកទេសនគរបាលបច្ចេកទេសវិទ្យាសាស្ត្រសំរាប់មន្ត្រីកងរាជអាវុធហត្ថ** (ពីថ្ងៃទី៤ដល់ថ្ងៃទី៨ខែវិច្ឆិកា ឆ្នាំ២០១៣)។ គោលដៅនៃកម្មសិក្សា ដែលមានទាំងទ្រឹស្ដី និងលំហាត់អនុវត្ត គឺដើម្បីពង្រឹងជំនាញមន្ត្រីកម្ពុជាផ្នែកស៊ើបអង្កេតយុត្តិធម៌ក្នុងរឿងព្រហ្មទណ្ឌ។

**ទស្សនកិច្ចរបស់ឯកឧត្ដម វ៉ាំងសង់ អេប្លេ** ប្រធានក្រុមមិត្តភាពព្រឹទ្ធសភាបារាំង-កម្ពុជា និងឡាវ ក្នុងឱកាសនៃការប្រារព្ធខួបទី៦០នៃទិវាឯករាជ្យថ្ងៃ៩ វិច្ឆិកា ឆ្នាំ២០១៣ របស់កម្ពុជា។ ឯកឧត្ដមត្រូវបានអមដំណើរដោយលោកជំទាវព្រឹទ្ធសភា ប៊ែរណាឌែត បួកហ្សេ ប្រធានប្រតិភូសំរាប់ប្រទេសឡាវ។ ទស្សនកិច្ចនេះបានឆ្លុះបញ្ចាំងអោយឃើញពីចំណងមិត្តភាពដែលភ្ជាប់ប្រជាជនបារាំង និងប្រជាជនកម្ពុជា។

**ទស្សនកិច្ចរបស់លោកជំទាវ អូរ៉េលី ហ្វីលីប៉េទី** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងគមនាគមន៍ នៅសៀមរាប ក្នុងក្របខ័ណ្ឌនៃសន្និសីទអន្តររដ្ឋាភិបាលលើកទី៣ ស្ដីពីអង្គរ (៥-៦ ធ្នូ ២០១៣)។ ក្នុងនាមជាសហប្រធានសន្និសីទដែលត្រូវបានរៀបចំឡើងដោយប្រទេសកម្ពុជានេះ លោកជំទាវហ្វីលីប៉េទីបានសំដែងការគាំទ្រឥតងាករេរបស់ប្រទេសបារាំង ដល់ការថែរក្សា និងលើកតំកើងបេតិកភណ្ឌកម្ពុជា។

**គណៈមេធាវីទីក្រុងប៉ារីស៍បានរៀបចំជំនួបអន្តរជាតិអាស៊ី**របស់ខ្លួននៅទីក្រុងភ្នំពេញ ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤។

ក្រោមការដឹកនាំរបស់ប្រធានគណៈមេធាវីលោកព្យែរ អូលីវីយេ សួរ ទិវានៃការបណ្ដុះបណ្ដាល និងការជួបជុំគ្នានេះបានផ្ដល់ឱកាសអោយមេធាវីបារាំងប្រមាណ១០០នាក់ សិក្សាស្វែងយល់អំពីបរិស្ថានគតិយុត្តិ និងបញ្ហាសេដ្ឋកិច្ចប្រទេសកម្ពុជា និងក្នុងតំបន់អាស៊ាន។

**ពិធីជូនដំណើរកងទ័ពមួកខៀវកម្ពុជា**ដែលទៅបំពេញបេសកកម្មនៅប្រទេសម៉ាលី ក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ។ ទាហានចំនួន៣០៩នាក់ នៃកងអនុសេនាធំដែលមានជំនាញក្នុងការដោះមីន និងកងអនុសេនាធំកងវិស្វកម្មត្រូវបានដាក់ពង្រាយនៅម៉ាលី ចាប់ពីដើមខែមីនា ឆ្នាំ២០១៤។

**ពិធីសម្ពោធមន្ទីរពិសោធន៍ស្រាវជ្រាវថ្នាក់តំបន់- អាស៊ីនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា។** មជ្ឈមណ្ឌលស្រាវជ្រាវថ្មីប្រកបដោយបច្ចេកវិទ្យាទំនើបនេះអាចទទួល និងបណ្ដុះបណ្ដាលអ្នកស្រាវជ្រាវកម្ពុជា និងអនុតំបន់ ដែលធ្វើការងារផ្នែកជំងឺឆ្លងថ្មី ឬជំងឺឆ្លងរាលដាលកកើតឡើងវិញ។

**ពិធីសម្ពោធអាគារថ្មីៗនៃវិទ្យាស្ថានបារាំងនៅកម្ពុជា។** កាលពីថ្ងៃទី២៦ ខែមីនា វិទ្យាស្ថានបារាំងបានបើកសម្ពោធភោជនីយដ្ឋានរបស់ខ្លួន ដែលបំរើម្ហូបបារាំង ព្រមទាំងរោងភាពយន្តដែលត្រូវបានជួសជុលកែលំអដោយស្ថាបត្យករ អ៊ីវ៉ង់ ទីស្សាណែល។ ការសម្ពោធនេះឆ្លុះបញ្ចាំងអោយឃើញអំពីភាពស្វាហាប់របស់វិទ្យាស្ថានក្នុងការផ្ដល់សេវាដ៏សំបូរបែបរបស់ខ្លួន។ វិទ្យាស្ថានបារាំងនៅកម្ពុជា: វិទ្យាស្ថានមួយដែលធ្វើចលនាឥតឈប់ឈរ និង ការចែករំលែកវប្បធម៌។

**សិក្ខាសាលា**នៅបណ្ឌិតសភាអក្សរចារឹក និងអក្សរសាស្ត្រនៃប្រទេសបារាំង លើប្រធានបទ "ពីរទសវត្សរ៍នៃកិច្ចសហប្រតិបត្តិការបុរាណវិទ្យាបារាំង-កម្ពុជានៅអង្គរ" កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៤ក្រោមព្រះរាជាធិបតីភាពរបស់ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថនរោត្តម សីហមុនី។ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានកោតសរសើរតួនាទីរបស់ប្រទេសបារាំងក្នុងការជំរុញអោយមានយុទ្ធនាការអន្តរជាតិដើម្បីអភិរក្ស និងលើកស្ទួយតំលៃបេតិកភណ្ឌអង្គរ ដែលជាគំនិតផ្ដួចផ្ដើមតែមួយគត់ក្នុងប្រវត្តិសាស្ត្របេតិកភណ្ឌវប្បធម៌ពិភពលោក។

© ព្រឹទ្ធសភាកម្ពុជា



© ស្ថានទូតបារាំងប្រចាំកម្ពុជា




© ហ្សេដើក ប៉េរ៉ូស្ស៊ែរ



© ប្រ៊ីហ្ស៊ីត អេម៉ាន់ បណ្ឌិតសភាអក្សរចារឹក និងអក្សរសាស្ត្រ





# កសិកម្ម ជាលក្ខណ:គ្រួសារ

ទីភ្នាក់ងារអភិវឌ្ឍន៍បារាំងទ្រទ្រង់កសិកម្មជាលក្ខណៈគ្រួសារដោយអនុញ្ញាតអោយអ្នកប្រកបរបរកសិកម្មតូចៗចងក្រងជារចនាសម្ព័ន្ធ មានលទ្ធភាពបង្កើនផលិតកម្ម និងឈានចូលទៅក្នុងទីផ្សារស្របតាមបទដ្ឋានគុណភាព និងទទួលផលចំណេញប្រកបដោយចីរភាព។











© Antoine Raab / Melon Rouge Agency





លោកងួន ឡាយ និងលោក កង់ហ្វាំង រដ្ឋមន្ត្រីប្រតិភូទទួលបន្ទុកការអភិវឌ្ឍនៅស្តង់របស់ទីភ្នាក់ងារអភិវឌ្ឍន៍បារាំងក្នុងឱកាសពិព័រណ៍កសិកម្មអន្តរជាតិ។





© AFD, Dominique Fradin

# ម្រេចកំពត

## ចូលរួមពិព័រណ៍កសិកម្មអន្តរជាតិ

ក្នុងឱកាសនៃឆ្នាំអន្តរជាតិនៃកសិកម្មជាលក្ខណៈគ្រួសារ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង(AFD) និងមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវក្បេត្រសាស្ត្រសំរាប់ការអភិវឌ្ឍន៍(CIRAD) បានរៀបចំស្តង់មួយនៅពិព័រណ៍កសិកម្មអន្តរជាតិឆ្នាំ២០១៤។

តាមរយៈកម្មវិធីផ្សេងៗ (មានការភ្លក់រសជាតិ សន្និសីទការសំភាសន៍)កិច្ចសហប្រតិបត្តិការបារាំងបានផ្តោតលើកសិកម្ម លក្ខណៈគ្រួសារជាគំរូនៃផលិតកម្មរួមទាំងមធ្យោបាយលើកកំពស់ការអភិវឌ្ឍន៍វិស័យនេះទៀតផង។ គំរូផលិតកម្មនេះមានគោលដៅឆ្លើយតបទៅនឹងបញ្ហាប្រឈមបីក្នុងសតវត្សទី២១: ផ្គត់ផ្គង់ម្ហូបអាហារដល់ភពផែនដី បង្កើតការងារធ្វើសមរម្យ និងប្រយុទ្ធប្រឆាំងការធ្វើអោយខូចបរិស្ថាន។

អ្នកទស្សនាចំនួន៥ ២០០នាក់បានភ្លក់ផលិតផលចំនួន១០ "ដែលផលិតក្នុងស្រុក" (ជាផលិតផលសំគាល់ភូមិសាស្ត្រ) ដែលទីភ្នាក់ងារអភិវឌ្ឍន៍បារាំងបានលើកស្ទួយនៅលើទីផ្សារ ជាពិសេសម្រេចកំពត និងស្ករត្នោតខេត្តកំពង់ស្ពឺ។

គឺនៅក្នុងក្របខ័ណ្ឌនេះហើយដែលលោក ងួន ឡាយ ប្រធានសមាគមលើកកំពស់ម្រេចកំពត ត្រូវបានអញ្ជើញអោយទៅធ្វើបទបង្ហាញអំពីផលិតផលទាំងពីរនេះ។ បន្ទាប់ពីការបង្កើតក្របខ័ណ្ឌច្បាប់ជាក់លាក់ការគាំទ្ររបស់ប្រទេសបារាំងផ្តោតលើការពង្រឹងសមត្ថភាពស្ថាប័ណអាជីព ការចេញលិខិតទទួលស្គាល់ និងការប្រយុទ្ធប្រឆាំងការបន្លំប្រើប្រាស់ឈ្មោះផលិតផល។ បន្ទាប់ពីទទួលបានម៉ាកសំគាល់ភូមិសាស្ត្រ តំលៃម្រេចកំពតបានកើនឡើង១០ដងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយតំរូវការនៅតែខ្ពស់ជាងការផ្គត់ផ្គង់។ ■

សំរាប់ព័ត៌មាន ⊕
www.afd.fr/home



© AFD, Dominique Fradin

### ▸ សក្ខីកម្មរបស់

**លោក ងួន ឡាយ**

*ប្រធានសមាគមលើកកំពស់ម្រេចកំពត*

*"ក្នុងឱកាសពិព័រណ៍កសិកម្មអន្តរជាតិខ្ញុំបានលើកតំកើងកិត្តិយសម៉ាកសំគាល់ភូមិសាស្ត្រទំនិញរបស់កម្ពុជា។ ប្រសិនបើគ្មានស្លាកយីហោនេះទេផលិតផលទាំងនេះប្រហែលបាត់ឈ្មោះទៅហើយ។ កិច្ចការដែលត្រូវធ្វើនៅមានច្រើនទៀត ដូចជាបង្កើនទំហំផ្ទៃដីដាំដុះ ផ្សព្វផ្សាយអំពីផលិតផល អភិវឌ្ឍទំនិញសំគាល់ភូមិសាស្ត្រ ពង្រឹងការត្រួតពិនិត្យ បង្ក្រាបការក្លែងបន្លំ ជួយកសិករតូចៗអោយទទួលបានហិរញ្ញប្បទាន។ ក្នុងន័យនេះហើយទើបការការពារកសិកម្មលក្ខណៈគ្រួសារមានសារសំខាន់។ ខ្ញុំមានសេចក្តីរំភើបចំពោះការយកចិត្តទុកដាក់របស់ប្រទេសបារាំងទៅលើវិស័យកសិកម្ម។ អនុស្សាវរីយ៍ដែលខ្ញុំមិនអាចបំភ្លេចបាននោះគឺការជួបជាមួយលោក កង់ហ្វាំង រដ្ឋមន្ត្រីទទួលបន្ទុកអភិវឌ្ឍន៍។ បន្ទាប់ពីទទួលបានបទពិសោធន៍នេះ ខ្ញុំចង់ជួយរៀបចំអោយមានពិព័រណ៍កសិកម្មមួយនៅប្រទេសកម្ពុជា។"*

# គំរោងទ្រទ្រង់កសិកម្ម

## ជាលក្ខណៈគ្រួសាររបស់ទីភ្នាក់ងារអភិវឌ្ឍន៍បារាំងនៅកម្ពុជា



© AFD, Eric Beugnot

នៅប្រទេសកម្ពុជាក៏ដូចជានៅប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀតដែរ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) ផ្តល់ហិរញ្ញប្បទានដល់គំរោងលើកកំពស់ផ្នែកកសិកម្មជាលក្ខណៈគ្រួសារ ជាពិសេសតាមរយៈការអភិវឌ្ឍវិស័យកសិកម្មពេញលេញ។ ដំណាំដែលទទួលបានការគាំទ្រពីបារាំងមានដូចជាកៅស៊ូ ម្រេច (សូមមើលអត្ថបទអំពីម្រេចកំពត) អង្ករ ឬស្បូត្រជាដើម។

សំរាប់ព័ត៌មាន ⊕
www.afd.fr/home/pays/asie/geo-asie/cambodge

ការគាំទ្រនេះសអោយឃើញតាមរយៈការធានាសុវត្ថិភាពដីធ្លី និងការលើកកំពស់ផលិតកម្ម (តាមរយៈការបង្កើនគុណភាពដី និងការប្រើប្រាស់អោយអស់លទ្ធភាពនូវធនធានធម្មជាតិ) ក៏ដូចជាការផ្តល់ហិរញ្ញប្បទានដល់កសិករ និងការលើកស្ទួយការលក់ដូរផលិតផល។ ប៉ុន្តែអ្វីដែលសំខាន់នោះ គឺការរៀបចំចងក្រងសមាគមអ្នកមានអាជីពដូចគ្នាឬខុសគ្នាតាមវិស័យនិមួយៗ (សមាគមកសិករ ឧស្សាហករ អ្នកនាំចេញ) ដូចករណីសមាគមអ្នកប្រើប្រាស់ទំនប់ការពាទឹកប្រៃព្រៃនប់ សមាគមកៅស៊ូកម្ពុជា ឬសហព័ន្ធស្រូវអង្ករកម្ពុជាជាដើម។

## "រៀបចំរចនាសម្ព័ន្ធអាជីព"

មកដល់ពេលនេះ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំងបានផ្តល់ប្រាក់កំចីចំនួនជិត៨៥លានអឺរ៉ូ ដើម្បីលើកទឹកចិត្តកសិកម្មជាលក្ខណៈគ្រួសារនៅប្រទេសកម្ពុជា។ ក្នុងពេលខាងមុខ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំងនឹងផ្តោតលើការផ្តល់ហិរញ្ញប្បទានដល់ទំនាក់ទំនងកិច្ចសន្យារវាងសហគ្រាសកសិឧស្សាហកម្ម និងក្រុមកសិករដើម្បីបង្កើនប្រាក់ចំណូលអ្នកប្រកបរបរក្នុងវិស័យកសិកម្ម និងបង្កើនតំលៃបន្ថែមនៅប្រទេសកម្ពុជា ដើម្បីវិវឌ្ឍឆ្ពោះទៅកាន់កំណើនប្រកបដោយចីរភាព។ ▪



© AFD, Eric Beugnot



## តើអ្វីទៅជាកសិកម្មលក្ខណៈគ្រួសារ ?

*ផ្ទុយពីការគិតជាទូទៅ កសិកម្មជាលក្ខណៈគ្រួសារគឺជាសកម្មភាពពាណិជ្ជកម្មដែលលើសពីកសិកម្មដើម្បីបំពេញតំរូវការចាំបាច់។មេគ្រួសារ និងសមាជិកគ្រួសារគឺជាកំលាំងពលកម្មផង និងជាម្ចាស់កសិកផលសំរាប់លក់ផង។ ជោគជ័យនៃការអភិវឌ្ឍកសិកម្មជាលក្ខណៈគ្រួសារនេះ សំខាន់ផ្អែកលើលទ្ធភាពទទួលបានដីឥណទាន និងទីផ្សារ ព្រមទាំងការរួមគ្នាជាក្រុមរបស់ផលិតករអោយទៅជាសមាគមអាជីព។*

សំរាប់ព័ត៌មាន ⊕
www.afd.fr/home/projets_afd/developpement_rural/agriculture-familiale



កសិកម្មជាលក្ខណៈ
គ្រួសារក្នុងពិភពលោកឆ្នាំ
២០១៤
ជាវិស័យ
ប្រើប្រាស់
កំលាំងពលកម្ម
ច្រើនជាងគេលើលោក

ស្រូបយក
៤០%
នៃប្រជាជនសកម្ម
ក្នុងពិភពលោក

ផលិត
ប្រមាណ ៨០%
នៃផលិតកម្មកសិកម្ម
ពិភពលោក

គោលដៅ
ដែលត្រូវសំរេច
២០៥០
ផ្គត់ផ្គង់ចំណីអាហារ
ដល់ប្រជាជន
៩ពាន់លាននាក់
ដែល៦៥%ជាអ្នក
រស់នៅតាមទីក្រុង។

# ព្រឹត្តិការណ៍នានា

## នៅត្រីមាសចុងក្រោយឆ្នាំ២០១៤ ជុំវិញកសិកម្មជាលក្ខណៈគ្រួសារ

ក្នុងក្របខ័ណ្ឌនៃឆ្នាំអន្តរជាតិនៃកសិកម្មជាលក្ខណៈគ្រួសារ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំងនឹងរៀបចំនៅទីក្រុងភ្នំពេញ នៅខែតុលា ឆ្នាំ២០១៤ នូវសន្និសីទមួយស្តីពី "កសិកម្មតាមកិច្ចសន្យា"។

- បញ្ហាបីជុំវិញការទទួលបានដីធ្លី ឥណទាន និងការរៀបចំរចនាសម្ព័ន្ធកសិករ នឹងត្រូវយកមកសិក្សាដោយផ្អែកជាពិសេសលើបទពិសោធន៍ក្នុងវិស័យអង្ករ កៅស៊ូ និងអាកាស្យាជាដើម។
- សន្និសីទនេះនឹងធ្វើឡើងជាបួនដំណាក់កាលគឺ

១ **សក្ខីកម្មរបស់កសិករ**

២ **ទស្សនកិច្ចកសិដ្ឋានវារីកសិកម្ម**នៅខេត្តកណ្តាល

៣ **ការរៀបចំវេទិកាតុមូល**ដែលមានការចូលរួមពីតំណាងក្រសួង ស្ថាប័នសាធារណៈ និងឯកជនស្ថាប័នផ្តល់ឥណទាន រួមទាំងតួអង្គសំខាន់ៗផ្នែកកសិឧស្សាហកម្ម

៤ **ពិព័រណ៍ផលិតផលកសិកម្ម** ជាលក្ខណៈគ្រួសារ

- បទយកការណ៍ពីរនឹងត្រូវធ្វើឡើងដោយវិទ្យុបារាំងអន្តរជាតិ (RFI) អំពីព្រឹត្តិការណ៍នេះផងដែរ។
- ពិព័រណ៍ក្រោមប្រធានបទ "កសិកម្មជាលក្ខណៈគ្រួសារ ឱកាសមួយសំរាប់ភពផែនដី ..." រៀបចំឡើងដោយ CIRAD និង AFD នឹងត្រូវបង្ហាញក្នុងឱកាសនោះដែរនៅវិទ្យាស្ថានបារាំងនៅកម្ពុជា។ ▪

នៅឆ្នាំ២០១៤
ក្នុងចំនោមអ្នកផ្តល់ជំនួយផ្សេងទៀត
**ទីភ្នាក់ងារអភិវឌ្ឍន៍បារាំងទ្រទ្រង់**
**គំរោងចំនួន១៥០នៅក្នុងពិភពលោក**




## តើត្រូវចូលរួមក្នុងការអភិវឌ្ឍកសិកម្មជាលក្ខណៈគ្រួសារដោយរបៀបណា ?

កសិកម្មជាលក្ខណៈគ្រួសារគឺជាឱកាសមួយសំរាប់ភពផែនដីដោយសារកសិកម្មប្រភេទនេះជាគំរូដ៏មានប្រសិទ្ធភាពបំផុតនៃការរៀបចំផលិតកម្ម ដើម្បីដោះស្រាយបញ្ហាសុវត្ថិភាពចំណីអាហារពិភពលោក បញ្ហាការងារ ការបន្សាំទៅនឹងបំលាស់ប្តូរអាកាសធាតុ និងការថែរក្សាបរិស្ថាន។ ជោគជ័យនេះអាចសំរេចបានលុះត្រាតែមានគោលនយោបាយសាធារណៈច្បាស់លាស់។



# បេតិកភណ្ឌ

ប្រទេសបារាំងទ្រទ្រង់ដល់ការអភិរក្ស និងលើកកំពស់តំលៃបេតិកភណ្ឌតាមរយៈគំរោងជួសជុល បណ្តុះបណ្តាល និងស្រាវជ្រាវ។

ផ្ទាំងសិលាចារឹកនៅប្រាសាទមេបុណ្យខាងលិច (K 528) សរសេរជាភាសាសំស្ក្រឹតនៅក្នុងឆ្នាំ ៩៥២។ ការផ្តិតទុកជាឯកសារកំពុងដំណើរការ។

© Léa Chamboncel / MNC EFEO





# ប្រាសាទមេបុណ្យខាងលិច

## ការបណ្តុះបណ្តាលតាមរយៈការជួសជុល

ចាប់តាំងពីឆ្នាំ១៩០៧មក ប្រទេសបារាំងចូលរួមចំណែកយ៉ាងសកម្មក្នុងការលើកស្ទួយតំលៃរមណីយដ្ឋានអង្គរតាមរយៈគំរោងជួសជុលនានា។ ក្នុងក្របខ័ណ្ឌនៃគំរោងកំពុងដំណើរការ ក្រៅពីការជួសជុលប្រាសាទ ដែលស្ថិតនៅចំកណ្តាលបារាយណ៍ខាងលិចនោះ ប្រទេសបារាំងសង្កត់ធ្ងន់លើការបណ្តុះបណ្តាលជំនាញបេតិកភណ្ឌ (ជាអាទិ៍ស្ថាបត្យករ និងបុរាណវិទូ ដែលធ្វើការក្នុងផ្នែកជួសជុលប្រាសាទ) ដោយសហការជាមួយមជ្ឈមណ្ឌលបេតិកភណ្ឌកម្ពុជា។

គំរោងធ្វើឡើងដោយមានកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយអាជ្ញាធរអប្សរាដែលមានតួនាទីសំរបសំរួលសកម្មភាពនានារបស់ក្រុមអ្នកជំនាញអន្តរជាតិប្រមាណ៣០ក្រុម ដែលកំពុងបំពេញការងារនៅតំបន់អង្គរ។

> "លើកស្ទួយតំលៃរមណីយដ្ឋានអង្គរ"

សាលាបារាំងចុងបូព៌ា (EFEO) ដែលជាដៃគូជាប្រវត្តិសាស្ត្រក្នុងការអភិរក្ស និងលើកស្ទួយតំលៃបេតិកភណ្ឌនៅកម្ពុជា និងក្នុងតំបន់គឺជាប្រតិបត្តិករដ៏សំខាន់នៅក្នុងគំរោងនេះ។ ក្នុងឱកាសនៃការបោះពុម្ពផ្សាយព្រឹត្តិបត្រនេះ ស្ថានទូតបារាំងសូមឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធលោក ប៉ាស្កាល់ រ៉ូយែរ ដែលបានទទួលមរណភាពកាលពីដើមឆ្នាំ។ លោកបានចំណាយកំលាំងកាយចិត្តអស់រយៈពេលជាច្រើនឆ្នាំ ដើម្បីលើកស្ទួយតំលៃតំបន់អង្គរ ជាពិសេសប្រាសាទបាពួន។ ▪



សិស្សសាលាបេតិកភណ្ឌធ្វើទស្សនកិច្ចសិក្សានៅការដ្ឋានជួសជុលប្រាសាទមេបុណ្យខាងលិច

© Sylvain Ulisse



កំណាយបុរាណវិទ្យានៅអតីតរាជធានីអង្គរធំ

© J. Gaucher (EFEO/MAFA)

# មជ្ឈមណ្ឌល
## បេតិកភណ្ឌកម្ពុជា

**មជ្ឈមណ្ឌលបេតិកភណ្ឌកម្ពុជាត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៧ ដោយមានការគាំទ្រពីប្រទេសបារាំង។ មជ្ឈមណ្ឌលនេះគឺជាគ្រឹះស្ថានសាធារណៈស្ថិតក្រោមឱវាទក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយមាននាយកដ្ឋានពីរផ្សេងគ្នា :**

នាយកដ្ឋានទី១គឺ **សាលាបេតិកភណ្ឌ** ដែលបង្កើតឡើងក្នុងកំរិតតំបន់ (ប្រទេសកម្ពុជា ឡាវ វៀតណាម) ក្នុងគោលដៅបណ្តុះបណ្តាលស្ថាបត្យករ បុរាណវិទូ និងវិស្វករលើការងារអភិរក្ស ក៏ដូចជាជួសជុលស្ថាបត្យកម្មបេតិកភណ្ឌទីក្រុង និងទេសភាព។

នាយកដ្ឋានទី២ គឺ**បេសកកម្មបេតិកភណ្ឌ** ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៥ ហើយបានក្លាយជានាយកដ្ឋាននៃមជ្ឈមណ្ឌលបេតិកភណ្ឌ នៅឆ្នាំ២០០៩ ដោយមានជំនាញក្នុងការធ្វើបញ្ជីសារពើភ័ណ្ឌ និងសិក្សាអំពីបេតិកភណ្ឌក្រោយសម័យអង្គរ ដែលគេមិនសូវស្គាល់ និងសិក្សា។

ចាប់តាំងពីការបង្កើតមក ស្ថាបត្យករប្រមាណ៦០រូបត្រូវបានបណ្តុះបណ្តាលក្នុងក្របខ័ណ្ឌនេះ ដោយសហការលើកម្មវិធីសិក្សាជាមួយសាលាសៃយ៉ូនៃទីក្រុងប៉ារីស ដែលមានជំនាញជាក់លាក់ក្នុងការបណ្តុះបណ្តាលស្ថាបត្យករបេតិកភណ្ឌ។ ▪

"សហការលើកម្មវិធីសិក្សា"



## ▶ បទសំភាសន៍

### លោកស្រី ម៉ែន ចន្ទ័ទេវី
*នាយិកាមជ្ឈមណ្ឌលបេតិកភណ្ឌ*

**តើហេតុអ្វីលោកស្រីបានសំរេចចិត្តបន្តការសិក្សានៅប្រទេសបារាំង ?**

*"បច្ចុប្បន្ន ខ្ញុំកំពុងសិក្សាថ្នាក់បណ្ឌិតស្ថាបត្យកម្មនៅសាលាស្ថាបត្យកម្មជាន់ខ្ពស់ក្រុងទូលូ ដែលនៅទីនោះខ្ញុំធ្វើការស្រាវជ្រាវអំពីវចនានុក្រមស្ថាបត្យកម្មខ្មែរ។ ក្នុងន័យនេះខ្ញុំបានទទួលអាហារូបករណ៍ពីរដ្ឋាភិបាលបារាំងដើម្បីធ្វើការងារស្រាវជ្រាវរបស់ខ្ញុំ។ ថ្វីបើគ្រួសារខ្ញុំជាអ្នកនិយាយភាសាបារាំង តែខ្ញុំជ្រើសរើសប្រទេសបារាំងក៏ដោយសារតែចំណងប្រវត្តិសាស្ត្រដែលភ្ជាប់ប្រទេសយើងទាំងពីរ ជាពិសេសក្នុងផ្នែកបេតិកភណ្ឌ។ ប្រទេសបារាំងជាចំណុចប្រសព្វនៃវប្បធម៌ ហើយខ្ញុំមានបំណងមោះមុតក្នុងការផ្ទេរតំលៃវប្បធម៌របស់បារាំងទៅដល់ស្ថាបត្យករ និងអ្នកជំនាញនគរូបនីយកម្មវ័យក្មេងកម្ពុជា។"*



ផ្ទាំងសិលាចារឹកភាសាសំស្រ្កឹត(K៤៨៥) ភិមានអាកាស អង្គរ ចុងសតវត្សរ៍ទី១២

© Léa Chamboncel / MNC EFEO

## កាលប្បវត្តិ (ជំនួយរបស់បារាំងក្នុងវិស័យបេតិកភណ្ឌនៅកម្ពុជា)

- **១៩០៧** សាលាបារាំងចុងបូព៌ាបានទទួលបន្ទុកក្នុងការថែរក្សាតំបន់អង្គរ
- **១៩៩០** ការចាប់បើកឡើងវិញនូវការដ្ឋានបុរាណវិទ្យាដោយសាលាបារាំងចុងបូព៌ានៅតំបន់អង្គរ
- **១៩៩៣** ការរៀបចំសន្និសីទអន្តររដ្ឋាភិបាលស្តីពីការអភិវឌ្ឍ និងអភិរក្សប្រាសាទអង្គរ លើកទី១ ការអនុម័តសេចក្តីថ្លែងការណ៍ក្រុងតូក្យូ ការបង្កើតគណៈកម្មាធិការអន្តរជាតិដើម្បីសំរបសំរួលកិច្ចគាំពារ និងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ (CIC Angkor) ដែលមានអង្គការយូណេស្កូជាលេខាធិការដ្ឋាន។ ប្រទេសបារាំង និងជប៉ុនជាសហប្រធានក្នុងចិរវេលាដប់ឆ្នាំដំបូង
- **១៩៩៥** ការបង្កើតអាជ្ញាធរអប្សរា
- **២០០៣** សន្និសីទអន្តររដ្ឋាភិបាលលើកទី២ ដើម្បីអភិរក្សតំបន់អង្គរ ការអនុម័តសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស៍។ ប្រទេសបារាំង និងជប៉ុនបន្តធ្វើជាសហប្រធានសំរាប់ចិរវេលាដប់ឆ្នាំទៀត។
- **២០០៧** ការបង្កើតមជ្ឈមណ្ឌលបេតិកភណ្ឌនៅប្រទេសកម្ពុជា
- **២០១១** ការបញ្ចប់ការដ្ឋានជួសជុលប្រាសាទបាពួន ក្រោមការដឹកនាំរបស់សាលាបារាំងចុងបូព៌ា។ ពិធីសម្ពោធផ្លូវការដោយព្រះមហាក្សត្រកម្ពុជា នរោត្តម សីហមុនី និងនាយករដ្ឋមន្ត្រីបារាំង ហ្វ្រង់ស័រ ហ៊្វីយ៉ុង។
- **២០១២** ការចាប់ផ្តើមការងារជួសជុលស្ពានប្រាសាទមេបុណ្យខាងលិច ក្នុងក្របខ័ណ្ឌនៃភាពជាដៃគូរវាងក្រសួងការបរទេសបារាំង សាលាបារាំងចុងបូព៌ា អាជ្ញាធរអប្សរា ក្រសួងវប្បធម៌បារាំង និងក្រសួងវប្បធម៌កម្ពុជា។
- **២០១៣** សន្និសីទអន្តររដ្ឋាភិបាលស្តីពីអង្គរលើកទី៣ ការអនុម័តសេចក្តីថ្លែងការណ៍ស្តីពីអង្គរ ការបន្តតំណែងជាសហប្រធានរបស់បារាំង និងជប៉ុនសំរាប់រយៈពេល១០ឆ្នាំទៅមុខទៀត។

# បេតិកភណ្ឌក៏ជា...

## ការស្រាវជ្រាវបុរាណវិទ្យាទីក្រុង

### តំបន់អង្គរធំ
*ដោយបុរាណវិទូ* ហ្សាក់ ហ្គោសេ

ក្រោមការដឹកនាំរបស់លោក ហ្សាក់ ហ្គោសេ ការស្រាវជ្រាវបុរាណវិទ្យានៅតំបន់អង្គរធំបានធ្វើអោយប្រាសាទនានាផុសចេញពីព្រៃ។ បន្ទាប់ពីការសិក្សាក្នុងតំបន់ដែលមិនទាន់នរណាស្គាល់ អ្នកស្រាវជ្រាវទាំងនោះបានបង្ហាញពីទស្សនៈវិស័យថ្មីមួយស្តីពីរាជធានីបុរាណខ្មែរ។

"រាជធានីបុរាណខ្មែរ"

ក្រុមការងារវិទ្យាសាស្ត្របារាំងបានអភិវឌ្ឍកម្មវិធីថ្មីមួយសំរាប់ស្រាវជ្រាវបុរាណវិទ្យាដោយផ្តោតលើអតីតរាជធានីទាំងមូលពោលគឺរួមទាំងបរិស្ថានជុំវិញ ហើយធ្វើការស្រាវជ្រាវតាំងពីប្រវត្តិអតីតកាលមក។ ដោយផ្អែកលើបច្ចេកវិទ្យាបុរាណវិទ្យានានា អ្នកស្រាវជ្រាវបានរកឃើញប្លង់នគរូបនីយកម្មនៃអតីតរាជធានីខ្មែរ។ កម្មវិធីខាងលើបង្ហាញថាតំបន់អង្គរធំគឺជាអតីតរាជធានីធំល្វឹងល្វើយ ដែលត្រូវបានរៀបចំជាច្រើនលើកច្រើនសារហើយក្នុងពេលមួយនោះមានមនុស្សរស់នៅយ៉ាងច្រើនកុះករ។

នៅពេលបច្ចុប្បន្ននេះ បេសកកម្មបុរាណវិទ្យាបារាំងនៅអង្គរធំកំពុងរៀបចំចងក្រងប្រវត្តិសាស្ត្រនេះឡើងវិញ ហើយនៅថ្ងៃខាងមុខ អ្នកបុរាណវិទ្យាអាចនឹងពិនិត្យលទ្ធភាពអនុវត្តការជួសជុលបែបថ្មី ដោយមិនផ្តោតតែទៅលើថ្មប្រាសាទប៉ុណ្ណោះទេ គឺត្រូវគិតអំពីទឹក និងព្រៃឈើជុំវិញផងដែរ។ ▪

## ការសិក្សាអំពីសិលាចារឹក

### សិលាចារឹកប្រទេសកម្ពុជាសម័យបុរាណ

*ដោយលោក ដូមីនិក ស៊ូទិហ្វ*
*អ្នកទទួលខុសត្រូវសាលាបារាំងចុងបូព៌ានៅខេត្តសៀមរាប*

*"សិលាចារឹកកម្ពុជាសម័យបុរាណ (សតវត្សរ៍ទី១០ដល់ សតវត្សរ៍ទី១៤នៃគ្រឹស្តសករាជ) គឺជាប្រភពសំខាន់ ដើម្បីចងក្រងប្រវត្តសាស្ត្រប្រទេសខ្មែរឡើងវិញ។ ជាក់ស្តែងតាមរយៈសិលាចារឹកទាំងនេះ គួបផ្សំនឹងឯកសារភាសាចិន យើងអាចដឹងអំពីការគ្រងរាជ្យជាបន្តបន្ទាប់ របស់ព្រះមហាក្សត្រខ្មែរ។*

"ប្រពៃណីយូរលង់"

*សិលាចារឹកទាំងនេះភាគច្រើនត្រូវបានសរសេរជាភាសាសំស្រ្កឹត ដែលជាភាសា "វប្បធម៌អាស៊ីតណ្ហា" និងភាសាខ្មែរបុរាណ ដែលជាដើមកំណើតភាសាខ្មែរសម័យបច្ចុប្បន្ន។ ការសិក្សាអំពីសិលាចារឹក គឺជាប្រពៃណីយូរលង់មកហើយរបស់សាលាបារាំងចុងបូព៌ា។ បច្ចុប្បន្ននេះអ្នកស្រាវជ្រាវនៃគំរោងសិលាចារឹកខ្មែរ (អនុវត្តដោយសាលាបារាំងចុងបូព៌ា និងសាលាអនុវត្តសិក្សាជាន់ខ្ពស់) កំពុងបន្តការធ្វើបញ្ជីសារពើភ័ណ្ឌផ្ទាំងសិលាចារឹក ដែលការងារនេះបានចាប់ផ្តើមធ្វើតាំងពីមួយសតវត្សរ៍មុនដោយលោក ហ្សក សឺដេស។ ពួកគេកំពុងខិតខំសិក្សា និងផ្សព្វផ្សាយអត្ថន័យរបស់សិលាចារឹកទាំងនោះ។"* ▪



# កងយោធពលខេមរភូមិន្ទ នៅក្នុងប្រតិបត្តិការរក្សាសន្តិភាព

**កាលពីមុន ប្រទេសកម្ពុជាទទួលបានការជួយជ្រោមជ្រែងពីកងទ័ពអង្គការសហប្រជាជាតិ ប៉ុន្តែបច្ចុប្បន្ននេះកម្ពុជាចូលរួមយ៉ាងសកម្មក្នុងប្រតិបត្តិការរក្សាសន្តិភាពពិភពលោក។ មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងរក្សាសន្តិភាព NPMEC មានមជ្ឈមណ្ឌលជំនាញកំរិតតំបន់មួយក្នុងវិស័យដោះមីន។**

ពិធីប្រគល់ទង់ និងធ្វើសច្ចាប្រណិធានរបស់កងទ័ពកម្ពុជាមុនពេលចេញដំណើរទៅប្រទេសម៉ាលីកាលពីខែកុម្ភៈ ឆ្នាំ ២០១៤

© ឯ.ឧ សែម សុវណ្ណី / NPMEC





# ប្រទេសបារាំង និង NPMEC*

*មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម

**មជ្ឈមណ្ឌល NPMEC កំពុងចូលរួមយ៉ាងសកម្មក្នុងប្រតិបត្តិការបោសសំអាតមីននៅកម្ពុជា។**

ក្រោមការដឹកនាំរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងជួយសង្គ្រោះជនពិការដោយសារមីន និងដោយសហការជាមួយដៃគូជាតិ និងអន្តរជាតិនានា មជ្ឈមណ្ឌល NPMEC បានបំពេញការងារដ៏គួរអោយកត់សំគាល់ក្នុងការបោសសំអាតតំបន់មានមីន និងគ្រឿងផ្ទុះ ជាពិសេសតំបន់ជាប់ព្រំដែនប្រទេសថៃ នៅខេត្តបាត់ដំបង និងខេត្តសៀមរាប។ សកម្មភាពទាំងនេះបានចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេស ដោយអនុញ្ញាតអោយគំរោងនានាអនុវត្តបានប្រកបដោយសុវត្ថិភាព ដូចជាការកសាងស្ពាន ថ្នល់ថ្នាក់ជាតិ និងតាមជនបទ ប្រព័ន្ធធារាសាស្ត្រ និងការធ្វើស្រែចំការជាដើម។

**មជ្ឈមណ្ឌល** NPMEC មានរចនាសម្ព័ន្ធពីរគាំទ្រដោយដៃគូអន្តរជាតិក្នុងក្របខណ្ឌនៃការបណ្តុះបណ្តាល និងការហ្វឹកហាត់គឺ :

- វិទ្យាស្ថានជាតិហ្វឹកហ្វឺនកងរក្សាសន្តិភាពនៅឧត្តុង្គ ដែលជាទីកន្លែងសំរាប់នាយទាហានធ្វើកម្មសិក្សាបណ្តុះបណ្តាល។
- សាលាហ្វឹកហ្វឺនកងកម្លាំងរក្សាសន្តិភាពពហុសាសន៍នៅកំពង់ស្ពឺ ដែលមានមុខងាររៀបចំប្រតិបត្តិការកងអនុសេនាធំ។

**ប្រទេសបារាំង**ដឹកនាំសកម្មភាពសហប្រតិបត្តិការសំខាន់របស់ខ្លួននៅវិទ្យាស្ថានឧត្តុង្គ។

**បញ្ហាប្រឈមដែលត្រូវជំនះ :**

- បង្ហាញថាខ្លួនជាមជ្ឈមណ្ឌលជំនាញថ្នាក់តំបន់នៅអាស៊ានលើផ្នែកដោះមីន។
- រក្សាការប្តេជ្ញាចិត្តចូលរួមប្រតិបត្តិការកំរិតខ្ពស់ក្រោមឆ័ត្រអង្គការសហប្រជាជាតិ និងលើកស្ទួយការចូលរួមរបស់ស្ត្រី។ ▪

*ការបង្ហាញពីការវិវឌ្ឍន៍តាមពេលវេលា*

**ពីខែតុលា ឆ្នាំ១៩៩១ ដល់ខែកញ្ញា ១៩៩៣:** មានប្រតិបត្តិការរក្សាសន្តិភាពអង្គការសហប្រជាជាតិចំនួនពីរនៅកម្ពុជា គឺ UNAMIC និង UNTAC ។

**ថ្ងៃទី១ ខែមីនា ឆ្នាំ ២០០៥:** រាជរដ្ឋាភិបាលកម្ពុជាសំរេចចិត្តចូលរួមប្រតិបត្តិការរក្សាសន្តិភាព អ.ស និងបង្កើតគណៈកម្មាធិការជាតិមួយសំរាប់សំរបសំរួលកិច្ចការបញ្ជូនកងកម្លាំង ។

**ថ្ងៃទី២ ខែមីនា ឆ្នាំ២០០៩:** តាមរយៈប្រកាសក្រសួង មជ្ឈមណ្ឌលហ្វឹកហ្វឺន បោសសំអាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ (TMCC) ត្រូវបានប្តូរទៅជាមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម (NPMEC)។



កម្មសិក្សាដោះមីន © ឯ.ឧ សែម សុវណ្ណី / NPMEC

**វគ្គសិក្សានានាដែលត្រូវបានរៀបចំឡើងដោយប្រទេសបារាំងនៅមជ្ឈមណ្ឌល NPMEC :**

- ✓ **ការបណ្តុះបណ្តាលភាសាបារាំង**សំរាប់ថ្នាក់ដឹកនាំ ដែលត្រូវបានចាត់តាំងទៅបំពេញបេសកកម្មរក្សាសន្តិភាពនៅប្រទេសនិយាយភាសាបារាំង
- ✓ **កម្មសិក្សា** EOD/IED ជាការបណ្តុះបណ្តាលបន្ថែមសំរាប់អ្នកជំនាញខ្មែរលើផ្នែកដោះមីន
- ✓ **កម្មសិក្សាតម្រួតយោធា**សំរាប់កងទាហានដែលត្រូវទៅបំពេញបេសកកម្មនៅប្រទេសស៊ូដង់
- ✓ **កម្មសិក្សានាយទាហានសេនាធិការ** ការបណ្តុះបណ្តាលសំរាប់នាយទាហានជាន់ខ្ពស់ ដើម្បីបំពេញការងារនៅសេនាធិការអង្គការសហប្រជាជាតិ
- ✓ **ពេទ្យជនបទកំរិត២** ជាការបណ្តុះបណ្តាលបន្ថែមសំរាប់គ្រូពេទ្យ និងគិលានុបដ្ឋាក





(រូបភាពខាងឆ្វេង) ▸ ការបណ្តុះបណ្តាលភាសាបារាំងក្នុងជួរកងទ័ព

(រូបភាពខាងស្តាំ) ▸ ពេទ្យជនបទនៅស៊ូដង់ខាងត្បូង

© ឯ.ឧ សែម សុវណ្ណី / NPMEC

# កងយោធពលខេមរភូមិន្ទនៅក្នុង ប្រតិបត្តិការរក្សាសន្តិភាព

■ ប្រតិបត្តិការបញ្ចប់រួចហើយ
■ ប្រតិបត្តិការកំពុងដំណើរការ




**បេសកកម្ម MINUS នៅស៊ូដង់**
ពីឆ្នាំ២០០៦ដល់២០១១
៥អង្គភាព = ៥២០នាក់

**បេសកកម្ម MINUSS នៅស៊ូដង់ខាងត្បូង**
ចាប់តាំងពីឆ្នាំ ២០១២
កងរាជអាវុធហត្ថ
៣ អង្គភាព = ២២០នាក់
ពេទ្យកំរិត២
៣ អង្គភាព = ២៣៧ នាក់

**បេសកកម្ម MINUSCA នៅអាហ្វ្រិកខាងត្បូង**
ខែសីហា ឆ្នាំ ២០១៤

**បេសកកម្ម MINURCART នៅអាហ្វ្រិកកណ្ដាល និងឆាត**
២០០៩ - ២០១០
១ អង្គភាព = ៤២ នាក់

**បេសកកម្ម MINUSMA នៅម៉ាលី**
តាំងពីឆ្នាំ២០១៤
កងអនុសេនាធំដោះមីននៅក្រុង GAO :
១៥៥នាក់
កងអនុសេនាធំវិស្វកម្មនៅ
KIDAL និងនៅ TESSALIT :
១៥៥នាក់

**បេសកកម្ម FINUL នៅលីបង់**
ចាប់តាំងពីឆ្នាំ ២០១០
៤ កងអនុសេនាធំ = ៨៣៨នាក់





ការហ្វឹកហាត់របស់កងរាជអាវុធហត្ថ
មុនពេលបំពេញភារកិច្ច
© ឯ.ឧ សែម សុវណ្ណី / NPMEC



## ▸ បទសំភាសន៍

វរសេនីយ៍ទោ អាត សំអឿន
មេបញ្ជាការកងតម្រួតយោធា
នៅស៊ូដង់ខាងត្បូង (MINUSS)

© ឯ.ឧ សែម សុវណ្ណី / NPMEC

**តើលោកអាចពណ៌នាអំពីបេសកកម្មរបស់កងកំលាំងកម្ពុជានៅស៊ូដង់ខាងត្បូងបានដែរឬទេ ?**

អង្គភាពតម្រួតយោធាខ្មែរនៅស៊ូដង់ខាងត្បូងជានាទូរសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធ និងមនុស្ស ព្រមទាំងត្រួតពិនិត្យចរាចរណ៍តាមផ្លូវថ្នល់ ដើម្បីដោះស្រាយអធិករណ៍ជាមួយប្រជាជន។ បន្ទាប់ពីមានព្រឹត្តិការណ៍ថ្មីៗនៅស៊ូដង់ខាងត្បូង យើងចូលរួមជាមួយអង្គភាពសន្តិសុខនានាក្នុងការឃ្លាំមើលជំរំជនភៀសខ្លួន និងចូលរួមផងដែរក្នុងការជានាលទ្ធភាពទទួលបានទឹកស្អាត។

**បើពិនិត្យទៅលើលក្ខណៈនៃបេសកកម្មប្រតិបត្តិការនេះ តើកងអនុសេនាធំរបស់លោកមានបានទទួលការជួយរៀបចំជាក់លាក់ណាមួយឬទេ ?**

ប្រទេសបារាំងបានបញ្ជូនមកប្រទេសកម្ពុជានូវអ្នកជំនាញរបស់ខ្លួនជាច្រើនរូប លើបេសកកម្មអង្គការសហប្រជាជាតិដើម្បីពង្រឹងសមត្ថភាពផ្នែកបច្ចេកទេស និងយុទ្ធសាស្ត្រនៃអង្គភាពនាយតម្រួតខ្មែរ។ ជាងនេះទៅទៀត ជំនាញការបារាំងនៃបេសកកម្មសហប្រតិបត្តិការ និងការពារអមអគ្គនាយក NPMEC បានចូលរួមយ៉ាងសកម្មក្នុងការបណ្ដុះបណ្ដាលរបស់យើងក្នុងផ្នែកយុទ្ធសាស្ត្រ ការសរសេរតាក់តែងនូវបទបញ្ជាបេសកកម្ម ផែនលេខា។ល។ ដូច្នេះកងអនុសេនាធំលេខ៧១១ បានទទួលបទពិសោធន៍ពីប្រទេសបារាំង។

**តើនាយទាហានផ្សេងទៀតរបស់អង្គការសហប្រជាជាតិយល់យ៉ាងណាដែរអំពីកងកំលាំងកម្ពុជា ?**

កងទ័ពកម្ពុជាបានទទួលការកោតសរសើរពីសំណាក់កងកំលាំងផ្សេងទៀតរបស់អង្គការសហប្រជាជាតិ។ វិធីសាស្ត្រ និងនីតិវិធីរបស់យើងជាញឹកញាប់មានលក្ខណៈស្រដៀងគ្នា។

**តើលទ្ធផលអ្វីខ្លះដែលលោកទទួលបានពីប្រតិបត្តិការនេះ ?**

ការចូលរួមក្នុងបេសកកម្មអង្គការសហប្រជាជាតិគឺជាបទពិសោធន៍ដ៏ប្រសើរ។ ការដែលយើងអាចធ្វើសហប្រតិបត្តិការ និងបំពេញការងារក្នុងបរិយាកាសពហុជាតិគឺផ្ដល់នូវចំនេះដឹងដល់យើងជាច្រើន ហើយជាងនេះទៅទៀតការទទួលបានការកោតសរសើរ និងការទទួលស្គាល់ពីប្រទេសផ្សេងៗទៀតចំពោះកំរិតជំនាញរបស់យើង គឺជាកិត្តិយសមួយសំរាប់កងទ័ពកម្ពុជា។




កងរាជអាវុធហត្ថកម្ពុជានៅស៊ូដង់ខាងត្បូង
© ឯ.ឧ សែម សុវណ្ណី / NPMEC


SOFITEL
LUXURY HOTELS
PHNOM PENH PHOKEETHRA
LE BRUNCH DU DIMANCHE
Une cuisine abondante
Du Champagne Veuve Clicquot illimité
Un duo pour vous séduire
Un espace pour les enfants et la journée à la piscine
De 11h30 à 14h30
De $55 à $70 avec Champagne par personne
(Prix excluant les taxes)
Sofitel Phnom Penh Phokeethra
26 Old August Site, Sothearos Blvd. - 023 999 200
www.sofitel.com/6526
En Famille ou Entre Amis
Toujours en Légèreté
Life is Magnifique in Phnom Penh!
www.sofitel.com
SOFITEL
LUXURY HOTELS


CAMBODIA
Beer


SANOFI


ATS
Your Trusted Partner in Electrical Solutions
Tableaux de distribution électrique et départs moteurs
Bancs de condensateurs basse tension
Transferts de source manuels et automatiques
Diagnostic et management énergétique
Systèmes de synchronisation pour générateurs
Accessoires électriques et pièces détachées
Assistance à la mise en service
Solutions dédiées en fabrication de tableaux électriques basse tension
Nos Produits:
Distribution Electrique
Contrôle Moteur
Efficacité Electrique
Protection contre la Foudre
Prises et Interrupteurs
Canalisations Electriques
Distributeur autorisé pour :
LS is
Schneider Electric
socomec
JEAN MULLER
Indelec
EDS
Mikro
enerlux
HENSEL
Advanced Technical Supplies


ហាងទឹកអប់
SCENTS 360°
SCENTS 360°
OFFICIAL FRAGRANCE DISTRIBUTOR IN CAMBODIA
Scents 360° outlets offer you a diverse range of perfumes.
You can find most of the prestigious international brands including Givenchy, Bvlgari, Burberry, Versace, Gucci, Hugo Boss, Paco Rabanne Dolce & Gabbana, and more which are directly and officially imported from Europe.
You can experience any kinds of perfumes with different scents including floral, fruity and woody. Our professional advisors are willing to share their secret tips on fragrances. Definitely you can find the most suitable fragrance for yourself.
- Riverside: #147, Sisowath Quay, Phnom Penh. 9:00am to 8:00pm
- Sovanna: Store #51-10, Sovanna Shopping Center, Phnom Penh, 9:30am to 8:45pm
Office Contact Tel: (855) 23 214 470
SCENTS 360°


UEXPRESS
« LOGISTIQUE INTERNATIONALE »
Transitaire au Cambodge depuis 1998
U-EXPRESS SERVICES :
Transport National et International
Service Porte-à-porte / Aérien et Maritime
Formalités Douanières – Import & Export
Logistique et Entreposage (15,000m2)
Distribution (105 dépôts au Cambodge)
Projets Industriels
GEOLINK GROUP
HEAD OFFICE:
No.41- 43 Norodom Blvd
Phnom Penh, Cambodia
Tel: 023 222 399
www.geolinkgroup.com
Agent
CLASQUIN
In Cambodia
STEPHANE GUIHARD / H/P (855) 90 333 549 / email: bdm@geolinkgroup.com.kh

# *L'ambassade de France tient à remercier les partenaires…*

# *… Et les fournisseurs*

RAFFLES LE ROYAL • POUR UN SOURIR D'ENFANT (PSE) • THAI HUOT MARKET • BONBON ICE CREAM • ASIA SUNRISES - CITY PREMIUM QUALITY • AUS KHMER • COMME À LA MAISON • LE VÔTRE • PCS CAMBODIA • LA PATATE







**SERVICE BANCAIRE ÉLECTRONIQUE**

*154 guichets automatiques dans le pays*
- Retrait d'espèces
- Règlement des factures d'électricité (Phnom Penh et province de Kandal)
- Recharge de téléphone (Hello, SMART, Beeline et Cellcard)

*CARTE ACLEDA*
- Carte de retrait
- Carte de retrait Gold
- Carte de crédit & de paiement international VISA ACLEDA

*POS*
- Avance de trésorerie
- Paiement de biens et services

*ACLEDA Unity*
- Retrait sans carte
- Règlement des factures d'électricité (Phnom Penh et provinces de Kandal, Sihanoukville, Kampot, Kampong Cham, Battambang et Siem Réap)
- Règlement des factures d'eau (Phnom Penh et province de Sihanouk)
- Transfert d'argent
- Recharge les téléphone mobiles (Beeline, Cellcard, CooTel, Excell, Metfone, OneTV, Online, qb, qbInt, Smart et Telecom Cambodge)
- Payer pour Angkor Net, Digi, EZECOM, Mega, Mekong Net, Online, Smart, et ACLEDA factures VISA de cart de crédit
- Paiement d'autres biens & services
- Consultation de solde
- Consultation des taux de change
- Et même plus…

**DÉPÔT**
- Compte d'épargne
- Compte courant
- Compte à dépôt régulier
- Compte chèque
- Compte de dépôt d'entreprise
- Compte épargne de retrait notifié
- Compte en fiducie pour immobilier
- Compte individuel retraite
- Compte épargne éducation
- Compte épargne santé
- Compte tenu en Euro

**FINANCEMENT COMMERCIAL**
- Lettre de crédit (import export)
- Titre interbancaire de paiement (import export)
- Garantie d'adjudication
- Garantie de bonne exécution
- Garantie de retenue de garantie
- Garantie de restitution d'acompte
- Garantie de paiement
- Garantie d'expédition

**GESTION DE LIQUIDITÉ**
- Service de paie
- Chèque de banque
- Achat de chèque étranger
- Voyageurs vérifie achat
- Chèque de banque
- Règlement de factures
- Compte de consolidation
- Paiement des fournisseurs
- Prélèvement bancaire
- Confirmation bancaire
- Service de change
- Prélèvement automatique pour les factures d'EDC
- Service de coffre-fort
- Service de paiement d'impôt
- Vente de la vignette automobile

**TRANSFERT D'ARGENT**
- Transfert local
- Transfert international (SWIFT, WESTERN UNION et Pay Easy Services)

**EMPRUNT**
- Prêt étudiant
- Autorisation de découvert pour les épargnants
- Prêt moto
- Prêt automobile
- Prêt pour micro-entreprise
- Prêt pour petite entreprise
- Prêt pour moyen entreprise
- Prêt personnel ou pour détaillant
- Découvert
- Ligne de crédit renouvelable
- Prêt au logement social
- Prêt rénovation de logement
- Prêt commercial

**CONSEIL BANCAIRE**

**PRODUIT DE TRESORERIE**
- Contrat de change à terme

Pour bénéficiez des services d'ACLEDA ou pour plus d'information, veuillez contacter notre service client 24h/24 :

**+855 (0)23 994 444 / +855 (0)15 999 233**

Site internet : www.acledabank.com.kh

La banque que vous pouvez avoir confiance. La banque pour le peuple

# LES CELLIERS D'ASIE

et ses producteurs français
vous souhaitent un joyeux 14 juillet!

CELLIERS D'ASIE

CHAMPAGNE TAITTINGER Reims

GRANDS CRUS CORDIER × MESTREZAT ·1886· ·1815· BORDEAUX

LOUIS JADOT

HENRI BOURGEOIS
SANCERRE ET POUILLY-FUMÉ

E.GUIGAL

TRIMBACH

Château Mont-Redon

BARON PHILIPPE DE ROTHSCHILD

COMPAGNIE VINICOLE BARON EDMOND DE ROTHSCHILD

LES DOMAINES BARSALOU

LARRESSINGLE

S.A.S MOULIN DE GASSAC ANIANE

LIQUEURS & SIROPS GIFFARD DEPUIS 1885

1863 CAMUS COGNAC

Perrier

Vittel

CELLIERS D'ASIE
No. 62B, St. 432, Sangkat Toul Tum Poung II, Khan Chamka Morn, Phnom Penh
Tel: 023 986 350 Fax: 023 986 351